*រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២៣*

# *សេចក្តីថ្លែងការណ៍រួម*

## *នាឱកាសនៃការផ្សព្វផ្សាយជាផ្លូវការនៃរបាយការណ៍តាមដានការអនុវត្តអនុសញ្ញាស៊ី-ដ ប្រចាំឆ្នាំ២០២២ សម្រាប់ប្រទេសកម្ពុជា ក្រុមអង្គការសង្គមស៊ីវិល សូមសំណូមពររាជរដ្ឋាភិបាល អោយចាត់នូវវិធានការចាំបាច់ដើម្បីអនុវត្តអនុសាសន៍របស់គណៈកម្មាធិការនៃអង្គការសហប្រជាជាតិទទួលបន្ទុកអនុសញ្ញាស៊ី-ដបន្ថែមទៀត*

យើងខ្ញុំតំណាងអោយក្រុមអង្គការសង្គមស៊ីវិលមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ សមាគម សហជីព ដូចមានរាយនាមខាងក្រោម សូមស្នើដល់រាជរដ្ឋាភិបាលកម្ពុជាដាក់ចេញនូវជំហានជាក់លាក់ ដើម្បីបង្កើនឡើងនូវសិទ្ធិមនុស្សរបស់ស្រ្តីនៅកម្ពុជា ។

គណៈកម្មាធិការនៃអង្គការមិនមែនរដ្ឋាភិបាលកម្ពុជា ដើម្បីអនុសញ្ញាលុបបំបាត់រាល់ទម្រង់នៃការរើសអើងលើស្រ្តី (NGO-CEDAW) រួមជាមួយអង្គការសង្គមស៊ីវិលជាដៃគូ កំពុងចេញផ្សាយនូវរបាយការណ៍តាមដានការអនុវត្តអនុសញ្ញាស៊ី-ដ សម្រាប់ឆ្នាំ២០២២ ។ របាយការណ៍នេះបានលើកយកនូវចំណុចជោគជ័យ និងឧបសគ្គនានាដែលទាក់ទងទៅនឹង ការអនុវត្តអនុសញ្ញាលុបបំបាត់រាល់ទម្រង់នៃការរើសអើងលើស្រ្តី (អនុសញ្ញាស៊ី-ដ) ។

របាយការណ៍នេះផងដែរ ក៏បានរំលេចឡើងនូវរបាយការណ៍វឌ្ឍនភាពស្តីពីជំហាននានាដែលរាជរដ្ឋាភិបាលកម្ពុជាបានធ្វើ ដើម្បីអនុវត្តអនុសាសន៍ របស់គណៈកម្មាធិការទទួលបន្ទុកអនុសញ្ញាស៊ី-ដ ឆ្នាំ២០១៩ ទៅតាមការពិនិត្យ ការអនុវត្តអនុសញ្ញា របស់រាជរដ្ឋាភិបាល។

យោងទៅតាមការរកឃើញពីការតាមដាន និងសិក្សាស្រាវជ្រាវរបស់យើងខ្ញុំ យើងខ្ញុំទាំងអស់គ្នាសូមធ្វើការសំណូមពរដល់រាជរដ្ឋាភិបាលកម្ពុជាមេត្តាដាក់ចេញ**ជា**ជំហានចាំបាច់នានាដូចខាងក្រោមនេះ ដើម្បីឆ្ពោះទៅរកភាពជោគជ័យក្នុងការអនុវត្តអនុសញ្ញាស៊ី-ដ៖

១) អនុវត្តអនុសាសន៍របស់គណៈកម្មាធិការទទួលបន្ទុកអនុសញ្ញាស៊ី-ដ ឆ្នាំ ២០១៣ ដើម្បីធានាអោយបានថាករណីអំពើហិង្សាលើស្ត្រី " ត្រូវបានកាត់ទោសប្រកបដោយប្រសិទ្ធិភាព ហើយមិនបញ្ជូនទៅរកយន្តការសម្រុះសម្រួលជាលក្ខណៈប្រព័ន្ធឡើយ" ។ ការធានាបែបនេះតម្រូវអោយបញ្ចប់នូវការអនុវត្តការផ្សះផ្សាទាំងស្រុង ហើយបង្កើតអោយមានការអនុវត្តជាស្តង់ដារក្នុងការបញ្ជូនករណីទៅតុលាការ ជាជាងទៅរកយន្តការដោះស្រាយ វិវាទក្រៅប្រព័ន្ធតុលាការ ។

២) អនុវត្តអនុសាសន៍របស់គណៈកម្មាធិការទទួលបន្ទុកអនុសញ្ញាស៊ីដ ឆ្នាំ២០១៩ ក្នុងការធ្វើកំណែទម្រង់ច្បាប់ ដោយធ្វើអោយទៅជាបទព្រហ្មទណ្ឌគ្រប់ទម្រង់នៃអំពើហិង្សាក្នុងគ្រួសារ និងផ្តល់នូវសិទ្ធិទទួលបានយុត្តិធម៌ និងដំណោះស្រាយប្រកបដោយប្រសិទ្ធិភាព ។

៣) ធ្វើវិសោធន៍កម្មច្បាប់ និងគោលនយោបាយនានា ស្តីពីការបោះឆ្នោតជាតិ និងមូលដ្ឋាន ដើម្បីបង្កើតប្រព័ន្ធឆ្លាស់នៃបញ្ជីបេក្ខជនឈរឈ្មោះនៃភេទខុសៗគ្នា ដើម្បីជានាអោយមានភាពស្មើគ្នា (ស្រ្តី៥០%) គ្រប់តំណែងជាថ្នាក់ដឹកនាំរាជរដ្ឋាភិបាល។

៤) ណែនាំការបណ្តុះបណ្តាលយេនឌ័រដល់គ្រូបង្រៀនទាំងអស់ និងការបង្រៀនអំពីសមភាពយេនឌ័រនៅក្នុងកម្មវិធីសិក្សារបស់សាលា។

៥) ធ្វើសកម្មភាពដើម្បីការពារ និងលុបបំបាត់ការបំពារបំពាន ហិង្សា និងទម្រង់ផ្សេងទៀតនៃការរើសអើងផ្អែកលើយេនឌ័រនៅក្នុងពិភពការងារ ដោយរួមទាំងវិស័យសារព័ត៌មាន តាមរយៈការអនុម័តគោល នយោបាយដែលរឹងមាំនានា និងផ្តល់សច្ចាប័នលើ អនុសញ្ញារបស់អង្គការពលកម្ម អន្តរជាតិ លេខ ១៩០ ដោយមិនពន្យារពេលតទៅមុខទៀតឡើយ ។

៦) ពង្រីកការទទួលបាននូវការថែទាំសុខភាពបន្តពូជដែលមានគុណភាព និងរួមបញ្ចូលការអប់រំផ្លូវភេទយ៉ាងទូលំទូលាយនៅក្នុងកម្មវិធីសិក្សារបស់សាលា។

### សម្រាប់ព័ត៌មានលម្អិតទៅតាមប្រធានបទសូមទំនាក់ទំនងមកកាន់៖

- ការចេញផ្សាយរបាយការណ៍៖ ជឹម ចាន់នាង អគ្គលេខាធិការ NGO-CEDAW ០១២ ៦៦៨ ៨៥៣
- អំពើហិង្សាផ្អែកលើយេនឌ័ររបស់ស្រ្តី និងក្មេងស្រីជនជាតិដើមភាគតិច និងជនជាតិភាគតិច៖

  អយ ម៉ារីនី ប្រធានគម្រោង អង្គការនារីដើម្បីសន្តិភាព ០៨៦ ៨៦០ ៤៣៣
- អំពើហិង្សា និងការបៀតបៀនលើកម្មករ និយោជិត៖ អ៊ូ ទេពផល្លីន ប្រធាន សហជីពចំណីអាហារ និងសេវាកម្មកម្ពុជា ០៩៨ ៩៨៤ ៨៨៣
- ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុមកលើកម្មករនិយោជិក និងសុខភាពស្ត្រី ៖ Louise GOLDMAN នាយិការងកម្មវិធីប្រចាំប្រទេស អង្គការ មជ្ឈមណ្ឌលសាមគ្គី ០១១ ៥៣២ ៥១០
- ការបៀតបៀន និងរំលោភបំពានតាមអន ឡាញ និងឃាតកម្មលើដៃគូស្និតស្នាល៖ អំ សំអាត នាយកអង្គការ លីកាដូ ០១២ ៣២៧ ៧៧០
- ផ្នត់គំនិតរើសអើងលើយេនឌ័រ និងឧបសគ្គ ចំពោះការអប់រំ៖ សង្វា ភួងវីណា ប្រធានកម្មវិធី តស៊ូមតិ និងបណ្តាញ អង្គការយេនឌ័រ និងអភិវឌ្ឍន៍ដើម្បីកម្ពុជា ០៧៧ ៨០៥ ០៦១

- ការប្រឈមរបស់ស្រ្តីក្នុងកិច្ចការនយោបាយ និងសារជារណៈ ៖ សឺនកេត សិរីលក្ខណ៍ អ្នកសម្របសម្រួលកម្មវិធីអប់រំ និងយេនឌ័រ នៃអង្គការខុមហ្រ្វែល ០១២ ៧៧៥ ៦៩៦

- ការប្រឈមចំពោះលទ្ធភាពក្នុងការទទួល បានការថៃទាំសុខភាពលើករណីអំពើហិង្សាផ្អែកលើយេនឌ័រ៖ សាផន សុមោលីរស្មី នាយិការរងប្រតិបត្តិ នៃអង្គការរ៉ាក់ ០៨៥ ២៥០ ៣៦៨

- លទ្ធភាពស្វែងរកយុត្តិធម៌លើករណីអំពើហិង្សាផ្អែកលើយេនឌ័រ៖ ម៉ៅ ម៉ាប់ នាយិកាអង្គការ ក្លាហាន ០៧៨ ៩៧៤ ០៤០